ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៣១/២៤ ន.គ.ស/សរ.ស.ចា.

ថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

## ស្តីពី

## វិធានការបន្ធូរបន្ថយលក្ខខណ្ឌនៃការប្រើប្រាស់ភាសាខ្មែរក្នុងបញ្ជីគណនេយ្យ និងឯកសារគាំទ្រគណនេយ្យ

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (អ.ស.ហ.) មានកិត្តិយសសូមជម្រាបជូន **លោក លោកស្រី** ជាម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ជ្រាបថា កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្លាប់បានផ្តល់ជូនសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ នូវភាពបត់បែនក្នុងការប្រើប្រាស់ភាសាក្នុងបញ្ជីគណនេយ្យ និងឯកសារគាំទ្រគណនេយ្យរួចម្តងមកហើយតាមរយៈ សារាចរណែនាំលេខ ០០៩ សហវ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការប្រើប្រាស់ភាសា និង រូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ។ លើសពីនេះ ដើម្បីជួយសម្រួលបន្ថែមដល់សហគ្រាស និងអង្គភាពមិនស្វែងរក-ប្រាក់ចំណេញសម្រាប់ការអនុវត្តកាតព្វកិច្ចគណនេយ្យពាក់ព័ន្ធនឹងការប្រើប្រាស់ភាសាខ្មែរក្នុងបញ្ជីគណនេយ្យ និងឯកសារគាំទ្រគណនេយ្យ ស្របតាមវិធានការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំពោះវិស័យឯកជន **និយ័តករគណនេយ្យនិងសវនកម្ម** ផ្តល់ការអនុញ្ញាត ដូចខាងក្រោម÷

១. សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើប្រាស់ភាសាអង់គ្លេស ក្នុងបញ្ជីគណនេយ្យ និងលើឯកសារគាំទ្រគណនេយ្យបាន ដោយពុំចាំបាច់បកប្រែទៅជាភាសាខ្មែរចាប់តាំងពីពេលដំបូងឡើយ។

២. សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវបានតម្រូវឱ្យបកប្រែចំណែក ឬចំណុចណាមួយនៃបញ្ជី ឬឯកសារទាំងនោះពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ក្នុងករណីមានការស្នើសុំពីមន្ត្រីនិយ័តករគណនេយ្យនិងសវនកម្ម កំឡុងពេលចុះត្រួតពិនិត្យប៉ុណ្ណោះ។

**និយ័តករគណនេយ្យនិងសវនកម្ម** សង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ ម្ចាស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងអស់ចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិង
សវនកម្ម សូមចូលរួមក្នុង Telegram Channel របស់
និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111